**ប្រការ ៤** : អគ្គនាយកវិទ្យុជាតិកម្ពុជា ប្រធាននាយកដ្ឋាន គ្រប់គ្រងការបោះពុម្ពផ្សាយសោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ មន្ទីរពត៌មានរាជធានីភ្នំពេញ និងអាជ្ញាធរដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

**ប្រការ ៥** : ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ខៀវ កាញារីទ្ធ**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៦

**សេចក្តីសំរេចលេខ ២០០/៩៦ ពម.សសរ**

**ស្តីពីការបង្កើតអនុគណៈកម្មការបច្ចេកទេស**

**កែទម្រង់រដ្ឋបាល ប្រចាំ ក្រសួង ពត៌មាន**

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១.១១.៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រម សន.រកម ០១៩៦.១៤ចុះថ្ងៃទី ២៤-០១-៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន ។
- បានឃើញលិខិតលេខ ២៦៧ សជណកបស ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ១៩៩៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញ សេចក្តីសំរេចលេខ ១៥៩-៩៦ ព.មសសរ ចុះថ្ងៃទី ១១.៦.៩៦ របស់ក្រសួងពត៌មានស្តីពីការបង្កើតគណៈកម្មការកែទម្រង់ រដ្ឋបាលប្រចាំក្រសួងពត៌មាន

-តាមការចាំបាច់របស់ក្រសួងពតិមាន

**សំរេច**

**ប្រការ ១** : បង្កើតអនុគណៈកម្មការបច្ចេកទេសកែទម្រង់រដ្ឋបាល ដើម្បីសំរួលការងារបច្ចេកទេសជូនគណៈកម្មការកែទម្រង់រដ្ឋបាលប្រចាំក្រសួងពតិមាន :

| | | |
|---|---|---|
| ១-លោក **ចាន់ សារុន** | អគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ | ជាប្រធាន |
| ២-លោក **ស៊ិន សុខ** | ប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក | ជាអនុប្រធាន |
| ៣-លោក **សោម បូរ៉ា** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិកអចិន្ត្រៃយ៍ |
| ៤-លោកស្រី **នង ហឿន** | ប្រធានការិយាល័យ អា កា ប៉េ | សមាជិក |
| ៥-លោក **ជ័យ ធុរ្ឍី** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦-លោកស្រី **មាស ម៉ូលី** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧-លោកស្រី **ឃាន់ មុន្នី** | នាយខុទ្ទកាល័យរដ្ឋមន្ត្រី | សមាជិក |
| ៨-លោក **អេន ឌុច** | ប្រធានការិយាល័យអគ្គាធិការដ្ឋាន | សមាជិក |
| ៩-លោក **ជា សារុន** | ប្រធានការិយាល័យកាសែតកម្ពុជា | សមាជិក |

**ប្រការ ២** : អនុគណៈកម្មការមានភារកិច្ច :

-ស្រាវជ្រាវនិងរៀបចំរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អគ្គនាយកដ្ឋាននីមួយៗ ។

-ពិភាក្សាកែតម្រូវជាលំអិតអោយបានសមស្របតាមភារកិច្ចរបស់អង្គភាព ។

-ស្រាវជ្រាវ និង រៀបចំលក្ខន្តិកៈដោយឡែកនៃមន្ត្រីរាជការក្រសួង ពតិមាន ។

-ឆ្លងយោបល់ ដើម្បីដាក់ជូនគណៈកម្មការបច្ចេកទេសកែទម្រង់រដ្ឋបាលប្រចាំក្រសួងពិនិត្យសំរេច ។

-ត្រូវរៀបចំដំណើរការជាបន្ទាន់ ។

**ប្រការ ៣** : លោកនាយកខុទ្ទកាល័យ លោកអគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ លោកអគ្គនាយក នាយកដ្ឋានចំណុះ និងលោក លោកស្រី ជាសមាជិកអនុគណៈកម្មការត្រូវអនុវត្ត តាមសេចក្តីសំរេចចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ខៀវ កាញារីទ្ធ**